# គណបក្ស ភ្លើងទៀន
# CANDLELIGHT PARTY
## សីលធម៌ សច្ចធម៌ យុត្តិធម៌

# សេចក្តីថ្លែងការណ៍

**គណបក្ស ភ្លើងទៀន** មិនអាចទទួលយកបានឡើយ ចំពោះសេចក្តីសម្រេចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) ដែលបានបដិសេធការចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣ របស់គណបក្ស ភ្លើងទៀន នៅថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០២៣ ដោយសំអាងមូលហេតុគណបក្ស ភ្លើងទៀន មិនបានភ្ជាប់ជាមួយនូវប្រកាសស្តីពី ការចុះឈ្មោះក្នុងបញ្ជីគណបក្សនយោបាយនៅក្រសួងមហាផ្ទៃ ដែលមានបញ្ជាក់នីត្យានុកូលកម្ម។

**គណបក្ស ភ្លើងទៀន** បានផ្តល់ឯកសារគ្រប់គ្រាន់ភ្ជាប់ជាមួយពាក្យសុំចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះ សម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣ នូវឯកសារចំនួន ០៣ (បី) ដែលបញ្ជាក់អំពីភាពស្របច្បាប់នៃការចុះបញ្ជីគណបក្ស ភ្លើងទៀន នៅក្រសួងមហាផ្ទៃ ដែលក្នុងនោះរួមមាន៖

១-ប្រកាសលេខ ១៩៣ ប្រក ចុះថ្ងៃទី២៣ ខែមីនា ឆ្នាំ១៩៩៨ របស់ក្រសួងមហាផ្ទៃ ស្តីពីការចុះឈ្មោះក្នុងបញ្ជីគណបក្សនយោបាយ (ច្បាប់ថតចម្លង)។

២-លិខិតលេខ ២០២៤ សជណ ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០១៧ របស់ក្រសួងមហាផ្ទៃ ស្តីពីការប្តូរឈ្មោះគណបក្ស សម រង្ស៊ី មកគណបក្ស ភ្លើងទៀន (មានបញ្ជាក់នីត្យានុកូលកម្ម)។

៣-លិខិតលេខ ០៤៣ ប ចុះថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០២៣ របស់ក្រសួងមហាផ្ទៃ ស្តីពីការបញ្ជាក់ថាគណបក្ស ភ្លើងទៀន បានចុះឈ្មោះក្នុងបញ្ជីគណបក្សនយោបាយនៅក្រសួងមហាផ្ទៃ ស្របតាមច្បាប់ស្តីពីគណបក្សនយោបាយ (មានបញ្ជាក់នីត្យានុកូលកម្ម)។

ឯកសារទាំង ០៣ (បី) ខាងលើនេះ បានបញ្ជាក់យ៉ាងច្បាស់អំពីភាពស្របច្បាប់ នៃការចុះបញ្ជីគណបក្ស ភ្លើងទៀន ក្នុងបញ្ជីគណបក្សនយោបាយនៅក្រសួងមហាផ្ទៃ ដែលក្រសួងមហាផ្ទៃបានទទួលស្គាល់ ស្របតាមច្បាប់ស្តីពីគណបក្សនយោបាយ។ ប៉ុន្តែ គ.ជ.ប នៅតែបដិសេធការចុះបញ្ជីគណបក្ស ភ្លើងទៀន សម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣។

**គណបក្ស ភ្លើងទៀន** យល់ឃើញថា សេចក្តីសម្រេចបដិសេធរបស់ គ.ជ.ប ចំពោះពាក្យសុំចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះ សម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣ របស់គណបក្ស ភ្លើងទៀន នៅពេលនេះ គឺៈ

១-ផ្ទុយពីចំណុចទី ១ នៃមាត្រា ២៧ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងប្រការ ៤.៧ ចំណុច ៤.៧.៣.១ នៃបទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ដែលបានកំណត់ឱ្យគណបក្សនយោបាយ ដែលបានដាក់ពាក្យចុះបញ្ជីឈរឈ្មោះបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ត្រូវជូនភ្ជាប់ជាមួយនូវសេចក្តីចម្លងលិខិតបញ្ជាក់ការចុះបញ្ជីគណបក្សនយោបាយ នៅក្រសួងមហាផ្ទៃ។ នេះបញ្ជាក់ថា ច្បាប់ និងនីតិវិធីរបស់ គ.ជ.ប ពុំបានតម្រូវឱ្យគណបក្សនយោបាយ ភ្ជាប់នូវប្រកាសរបស់ក្រសួងមហាផ្ទៃ ដែលមានបញ្ជាក់នីត្យានុកូលកម្មនោះឡើយ។

២-ផ្ទុយពីការអនុវត្តការងាររៀបចំការបោះឆ្នោតនាពេលកន្លងមក ទាំងការបោះឆ្នោតថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដែល គ.ជ.ប បានទទួលស្គាល់ការចូលរួមរបស់គណបក្ស ភ្លើងទៀន រួមទាំងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់ឆ្នាំ២០២២ ជាពិសេសការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាក្រុង-ស្រុកដែលទើបបំបែក និងបង្កើតថ្មី ដែលបានប្រព្រឹត្តទៅកាលពីថ្ងៃទី០៩ ខែមេសា ឆ្នាំ២០២៣ ថ្មីៗកន្លងមកនេះ។

៣-ជាការបដិសេធមិនទទួលស្គាល់លិខិតគតិយុត្តិរបស់ក្រសួងមហាផ្ទៃ ដែលជាស្ថាប័នមានសមត្ថកិច្ចក្នុងការចុះបញ្ជីទទួលស្គាល់គណបក្សនយោបាយ ស្របតាមច្បាប់ស្តីពីគណបក្សនយោបាយ។

**គណបក្ស ភ្លើងទៀន** នឹងរៀបចំសំណុំឯកសារដាក់ពាក្យបណ្តឹងតវ៉ា ចំពោះសេចក្តីសម្រេចរបស់ គ.ជ.ប ទៅក្រុមប្រឹក្សាធម្មនុញ្ញ ហើយមានជំនឿយ៉ាងមុតមាំថា ក្រុមប្រឹក្សាធម្មនុញ្ញ នឹងចេញសេចក្តីសម្រេចយល់ព្រមឲ្យគណបក្ស ភ្លើងទៀន ចុះឈ្មោះក្នុងបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះសម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣ ជាផ្លូវការ៕

**ថ្ងៃចន្ទ ១១រោច ខែពិសាខ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧**

**រាជធានីភ្នំពេញ, ថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០២៣**

**គណបក្ស ភ្លើងទៀន**

**ព័ត៌មានបន្ថែមសូមទាក់ទង:**

- ០៧៨ ៤៤ ៦៥ ៨៨